# យោបល់លោកនាយកមធ្យមសិក្សាចំពោះ

# បញ្ហាខេមរនីយកម្ម

គ. នាយកសមាគមយើង បានផ្ញើលិខិតមួយស្ដីពីផែនការខ្លះនៃខេមរនីយកម្ម ( ដែលចុះក្នុងទំព័រទី ១ ) ទៅជូនសហជីវិនីរដ្ឋលេខាធិការក្រសួងអប់រំជាតិ ។ សហជីវិនីក៏បានផ្ញើលិខិតរបស់យើងនេះ ទៅសួរយោបល់លោកនាយកមធ្យមសិក្សា ។ ចំពោះសំនួរខាងលើ លោកនាយកមធ្យមសិក្សាបានបង្ហាញយោបល់របស់លោកជូនសហជីវិនីរដ្ឋលេខាធិការវិញ នៅក្នុងលិខិតមួយចុះថ្ងៃ ១៩ ខែធ្នូ ១៩៦៦ ។

យើងមានសេចក្ដីរីករាយជាពន់ពេក នឹងចុះផ្សាយយោបល់លោកនាយកមធ្យមសិក្សា ដែលយើងសូមគាំទ្រទាំងស្រុងថា ជាយោបល់ត្រូវតាមការពិត នឹងល្អប្រសើរក្រៃលែង ដូចតទៅនេះ :

REPONSE AU BULLETIN DE SOIT COMMUNIQUE

N° 357-ID du 24-11-66

នាយកមធ្យមសិក្សា

សូមជំរាបមកសហជីវិនីរដ្ឋលេខាធិការក្រសួងអប់រំជាតិ

សូមទានជ្រាប

បញ្ហាខេមរនីយកម្ម ដែលគណៈកម្មាធិការនាយកនៃសមាគមសាស្ត្រាចារ្យបានលើកយកមកចោទស្នើក្នុងនាទីនេះ ជាបញ្ហាដែលនាយកដ្ឋានមធ្យមសិក្សាបានលើកយកមកពិនិត្យជាច្រើនលើករួចមកហើយ នៅពេលប្រជុំនាយកវិទ្យាល័យ និងអនុវិទ្យាល័យនានា ។

ដោយបញ្ហានេះ ជាប់ទាក់ទងទៅនឹងនយោបាយសិក្សាទូទៅនឹងកត្តាឯទៀតៗជាច្រើន អន្ទង់ទៅលើមតិ គំនិត ទំលាប់និយម ការស្ទិតស្ទាញ ការប្រកាន់វាយតម្លៃ ។ល។

នាយកដ្ឋានមធ្យមសិក្សាក៏បានចាត់ទុកបញ្ហានេះស្ទះមួយអន្លើសិន ។ តែការចាត់ទុកបញ្ហាបែបនេះ ឲ្យសម្ងំស្ងៀមដូច្នេះ ពុំសន្មត់ថា ក្រុមក្រសួងខ្ញុំព្រងើយកន្តើយក៏ទេដែរ ។

បញ្ហាដ៏ធំនេះ អាចបង្កើតនូវភាពកោលាហលផ្សេងៗ ហើយអនុភាពនៃបញ្ហានេះ វាមានទំហំន័យជ្រុលផុតហួសពីក្របខណ្ឌសមត្ថកិច្ចនៃនាយកដ្ឋានខ្ញុំផង ។

★

តាមមតិរបស់ខ្ញុំផ្ទាល់ ក្នុងឋានៈខ្ញុំជាសាស្ត្រាចារ្យមួយរូបដែរ ជាភ្នាក់ងាររាជការមួយរូបទទួលខុសត្រូវលើបញ្ហានេះដែរ បញ្ហាខេមរនីយកម្មនេះគួរតែលើកមកដោះស្រាយ ព្រោះការដោះស្រាយនេះ មានភាពហួសពីការសមរម្យទៅទៀត ។ ការសំអាងទៅលើភាពសមរម្យនេះ គឺមានន័យស្របទៅលើទេសៈកាលៈបច្ចុប្បន្ននៃប្រទេសយើង ដែលវិវត្តទៅរកវឌ្ឍនភាពកាន់តែមាំទាំនឹងស្ថាពរទៀតផង :

១– ប្រទេសឯករាជ្យនានាក្នុងពិភពលោក តែងចាប់អារម្មណ៍ធំបំផុតណាស់លើបញ្ហាភាសាជាតិគេ ដោយគេលើកនូវតម្លៃភាសាជាតិគេរៀងៗខ្លួន ឲ្យមានភាពគ្រប់គ្រាន់រុងរឿងឡើង សំអិតសំអាងរចនាឲ្យភាសាជាតិរបស់គេ បានឈានដំហានទៅកាន់ប្រសិទ្ធិភាព ទាំងខាងការប្រាស្រ័យទាក់ទងគ្នានឹងគ្នាជាផ្លូវសាមញ្ញក្តី, ទាំងខាងអក្សរសិល្ប៍ (Littérature) ក្តី ទាំងខាងការសិក្សាវិទ្យាសាស្ត្រទូទៅក្តី ។

**ភាសាជាតិជានិមិត្តរូប នៃប្រជាជាតិប្រកបដោយកិត្យានុភាព និង បូរណភាពពេញលេញ ។**

ប្រទេសនានានៅអាស៊ីទ្វីបដែលបានទទួលឯករាជ្យបរិបូណ៌ ដូចជា ចិន ជប៉ុន យួនជាដើម បានខិតខំដំកើងភាសាជាតិគេ ពុំត្រឹមតែនៅបឋម ឬមធ្យមសិក្សាប៉ុណ្ណោះទេ គេមានការក្លាហានហ៊ានជម្រុលបញ្ហាបញ្ចូលភាសាជាតិគេ ជាភាសាឈានទៅក្នុងឧត្តមសិក្សាទៀតផងៗ

ប្រទេសកម្ពុជាឯករាជ្យគួរតែភ្ញាក់រលឹកត្រង់ចំណុចភាសាជាតិនេះដែរ បានសេចក្ដីថា យើងពុំមែនដើរស្របតាមតម្រាយដែលគេបានគ្រាយគ្រួសនោះទេ គឺយើងមានបញ្ហារបស់យើងផ្ទាល់ ដោយឡែក ។

២– ក្នុងរដ្ឋធម្មនុញ្ញយើងទៀត ខេមរភាសា ក៏បានចាត់ជាភាសាផ្លូវការដែរ ។ ដូច្នេះ បើប្រសិនជាយើងដែលជាខេមរជាតិ ព្រងើយកន្ដើយពុំព្រមប្រតិបត្តិ នូវលក្ខខណ្ឌនៃរដ្ឋធម្មនុញ្ញនេះ នោះហាក់ដូចជាពុំសូវសមរម្យដែរ ។

៣– ការយោលយកខេមរភាសា ជាភាសាយានក្នុងការសិក្សា អាចនាំមកនូវប្រសិទ្ធិភាពច្រើនសណ្ឋាន :

ក.– ការរៀន ការបង្រៀន ការពន្យល់ នូវមុខវិជ្ជានានាអាចទទួលនូវភាពងាយ សិស្សានុសិស្សអាចស្ដាប់ឆាប់យល់ នូវមុខវិជ្ជានីមួយ ៗ ព្រោះជាភាសាដែលសិស្សានុសិស្សធ្លាប់ប្រើនៅគ្រប់ទីកន្លែង ទោះជានៅក្នុងចំណោមគ្រួសារក្ដី ទោះជានៅក្នុងសាលារៀនក្ដី ទោះជានៅទីដទៃឯទៀតក្ដី ។

ខ.– យើងចំណេញថវិកាជាតិយ៉ាងសម្បើមក្នុងករណីយកិច្ចនេះ ដោយយើងលែងពឹងផ្អែកលើបុគ្គលិកសាស្ត្រាចារ្យបរទេសទៀត ដូចជាសាស្ត្រាចារ្យបារាំងជាដើម ដែលជាកត្តាបង្កើតនៅបញ្ហាស្មុគស្មាញជាច្រើន មានបញ្ហាផ្ទះសម្បែង បញ្ហាចំណាយប្រាក់ទិញសំបុត្រកប៉ាល់ហោះទៅកំសាន្តសំរាកនៅប្រទេសគេវិញជាដើម ។

យើងបានចំណាយនូវឥណទានដ៏ច្រើនសម្រាប់ថ្លៃឈ្នួលផ្ទះ សម្រាប់សង់អាគារដ៏ប្រណិតប្រកបដោយផាសុកភាព ដើម្បីតម្រូវចិត្តនៃសាស្ត្រាចារ្យបរទេសទាំងនោះ ។ បើនិយាយអំពីការកិច្ចកក់ ញ៉ាំញ៉ូវនៃសាស្ត្រាចារ្យទាំងនោះវិញ ការធ្វើពលិកម្មដ៏សម្បើមខាងឥណទាន ខាងការខិតខំសម្រួលឲ្យបរទេសគេពេញចិត្ត បានលទ្ធផលពុំជួនល្មមនឹងការដែលសាស្ត្រាចារ្យបរទេសទាំងនោះផ្ដល់មកឲ្យវិញសោះ ។ ត្រង់ចំណុចនេះ មានអស់

*លោកខ្លះ ពិតជាមានប្រសាសន៍បញ្ចេញមតិថាជាពិតដូចតទៅនេះ : ការពុំបានទទួលផលប្រសើរពីសាស្ត្រាចារ្យទាំងនោះ ពុំមែនមកពីសាមីខ្លួនបារាំងទាំងនោះទេ ប្រហែលមកពីក្រុមក្រសួងដែលត្រួតពិនិត្យនោះហើយ—ត្រង់នេះ នរជនណាក៏ជ្រាបដែរថា សាស្ត្រាចារ្យបារាំងវាបំពេញការងារយ៉ាងណា ថ្វីបើមានអធិការកិច្ច ការត្រូវមានឲ្យតែអាកប្បកិរិយាឲ្យស្រប តាមបទបញ្ជា ឬ បញ្ញត្តិយ៉ាងណាក៏ដោយ ។*

*ក្នុងករណីនេះ បើប្រៀបធៀបសាស្ត្រាចារ្យខ្មែរមួយរូបទៅ នឹងសាស្ត្រាចារ្យបារាំងមួយរូបដែលមានសញ្ញាបត្រប្រកបដោយកំរិតប្រហែលគ្នា លទ្ធផលដែលសាស្ត្រាចារ្យខ្មែរហុចមក មានទំហំសារៈប្រយោជន៍ខ្ពស់ត្រដែតជាងសាស្ត្រាចារ្យបារាំងរូបនោះឯង គឺពិតជាស្រប ទៅតាមតម្លៃ វិនិយោគ (investissement) របស់យើងខាងថវិការ ខាងកម្លាំងពលំ ខាងកម្លាំងចិត្ត ។ ហេតុដែលនាំឲ្យបានទទួលនូវលទ្ធផលល្អប្រសើរបែបនេះ គឺពិតជាមកពី :*

- *ការស្រឡាញ់ជាតិរបស់សាស្ត្រាចារ្យខ្មែរ*
- *ការខិតខំប្រឹងប្រែងឲ្យសមនឹងឋានៈខ្លួនជាពលរដ្ឋខ្មែរ*
- *ការស្រាវជ្រាវរកនូវមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីពន្យល់សិស្សឲ្យបាន ឆាប់យល់ ងាយយល់....*
- *ពិសេសទៅទៀត មានការប្រើភាសាជាតិខ្លះៗផង*

សាស្ត្រាចារ្យបារាំង ក្នុងករណីបង្រៀនសិស្សានុសិស្សខ្មែរ ប្រើភាសាបារាំងសុទ្ធសាធដូច្នេះ ជួបប្រទះនឹងការលំបាកជាច្រើន ម្ល៉ោះហើយសាស្ត្រាចារ្យទាំងនោះក៏ចាត់តាំងកូនសិស្សខ្មែរជាពពួកសិស្សខ្សោយណាស់ រួចក៏តាំងវាយតម្លៃបន្ទោកបង្អាប់នូវគុណសម្បត្តិរបស់សិស្សខ្មែរភ្លាម លើកដំកើងសិស្សបរទេសសាសន៍ស្បែក ស ឬពួកកែតាំងពីដូនតាគេមក ។

គ. — ការសិក្សាវិទ្យាសាស្ត្រទូទៅទើបអាចចាត់ទៅជាចំណានបាន ក៏ពុំមែនទាល់តែរៀនវិទ្យាសាស្ត្រនោះ ដោយពឹងផ្អែកទៅលើភាសាសាសន៍ស្បែកស ជាពន្ទឺនោះក៏ទេដែរ ។ ការចេះ ការចាប់យល់នូវពុទ្ធិ (la connaissance) ដែលមានក្នុងវិទ្យាសាស្ត្រទាំងនោះបានក៏អាស្រ័យនូវភាសាយានណាមួយ ៗ ភាសាយាននេះ ទោះជាភាសាពពួកអ្នកប្រាជ្ញ ទោះជាភាសាពពួកស្បែកស ក៏ពុំអាចមានអនុភាពអ្វីដល់សិស្សានុសិស្ស ដែលសិក្សានូវវិទ្យាសាស្ត្រនោះដែរ បានសេចក្តីថា គ្រាន់តែប្រើភាសាសាសន៍ស្បែកស ហើយពុំប្រើនូវការត្រិះរិះពិចារណាលើជម្រៅន័យនៃវិជ្ជាទាំងនោះ លទ្ធផលក៏ពុំបានមកងាយ ៗ ដែរ ។ អស់លោកវរជនមុខជានឹងមានយោបល់ថា : "ទេ ! រៀនវិទ្យាសាស្ត្រ ដោយប្រើភាសាខ្មែរជាយានម្តេចទៅកើត ព្រោះខេមរភាសាយើងខ្វះនូវពាក្យសព្ទផ្នែកខាងតិចនិចនោះទាំងស្រុង — យើងមានតែភាសាបាលី សំស្ក្រឹត ដែលពុំអាចជ្រួតជ្រាបដល់ទៅគ្រប់គ្នា រួចអស់លោកមានសញ្ញាប័ត្រធំ ៗ ដែលជាជាតិខ្មែរ ក៏ពុំមានចំណេះខាងភាសាខ្មែរ ឲ្យបានមាំទាំដែរ" ។

មតិនេះក៏ត្រូវដែរ តែបើយើងចាំនូវកុសលផលបុណ្យហុចមកឲ្យយើង នោះប្រហែលជាពុំដើរទៅមុខទេ យើងមុខជានៅកន្លែងដដែល យើងនៅតែពឹងផ្អែកលើសាស្ត្រាចារ្យបារាំងដដែល យើងនៅតែធ្វើបែបដូចសព្វថ្ងៃដដែល យើងនៅតែស្ទាក់ស្ទើរដដែល យើងនៅតែដោះស្រាយអ្វីក៏ពុំរួចដដែល ។

បើអ្នកសិក្សាពុំសូវមានចំណេះច្បាស់លាស់ខាងភាសាបារាំង ដែលជាភាសាយានសព្វថ្ងៃ ការតានតឹងមាននៅលើសិស្សានុសិស្សខ្មែរជានិច្ច ណាមួយគ្នាខំព្យាយាមខាងភាសា ណាមួយខំប្រឹងប្រែងឲ្យបានយល់នូវវិទ្យាសាស្ត្រ ដូច្នេះឃើញថា សិស្សានុសិស្សខ្មែរចាប់យកវិជ្ជាមកសំគីដល់ទៅពីរព្រម ៗ គ្នា ៗ ដល់សម្រេចលទ្ធផលជាអវសាន ទៅជា

ស្អាក់ស្ទើរទាំងសងខាង ។ បើឃើញគុណវិបត្តិដូច្នេះហើយ ម្តេចក៏យើងទទូចចង់យកបញ្ហាខេមរនីយកម្មមកដោះស្រាយទៀត ? ចម្លើយតែមួយដែលខ្ញុំអាចជូនជាវិភាគទាន

គឺពិតជា ការចាំបាច់របស់ប្រទេសយើងឯករាជ្យ ដែលត្រូវរស់ដោយខ្លួនឯង ពឹងលើសមត្ថភាពរបស់ខ្លួនឯង ស្របតាមមតិអ្នកជាតិនិយមពិត ៗ ។

៤– តែបើប្រសិនជាយើងយកបញ្ហាខេមរនីយកម្មមកដោះស្រាយ ការលំបាកមុខជាមាន ឧបសគ្គនឹងលេចឡើងច្រើនប្រាកដជាពុំខាន តែក្នុងនាទីនេះ ខ្ញុំគ្រាន់តែសូមញែកជាករណី ដែលមានអត្ថប្រយោជន៍ (avantages) នឹងករណីដែលមានអត្ថទោស (les inconvénients) មកលាតត្រដាងប៉ុណ្ណោះ ដើម្បីល្បងជូនយោបល់នឹងគោលរបស់ខ្ញុំផ្ទាល់ចំពោះបញ្ហានេះ :

## ក.– អត្ថប្រយោជន៍

ក្នុងបច្ចុប្បន្នកាលនេះ យើងកំពុងតែពិនិត្យរៀបចំកែទម្រង់កម្មវិធីសិក្សានៅមធ្យមសិក្សាតាមរបៀប A, B, C ដែលសម្តេចសហាជីវិនព្រះអង្គទ្រង់បាន ព្រះរាជតម្រិះកំណត់ជាគោលការណ៍ទុកមកហើយ ។ កិច្ចការក៏យើងបានជម្រុលធ្វើរួចទៅហើយដែរ ។ តាមរបៀប A, B, C នេះ កម្មវិធីសិក្សាថ្មីសំដៅទៅរកចំណុចបច្ចេកទេស បានសេចក្តីថាសិស្សានុសិស្សនឹងត្រូវតម្រូវឲ្យចាប់យកវិជ្ជាបច្ចេកទេសច្រើនជាងវិជ្ជាជាទ្រឹស្តី ។ បើដូច្នេះ ការចាប់យកខេមរភាសា ជាយានក្នុងការហ្វឹកហ្វឺន ក្នុងការសិក្សា មុខជាប្រទះនឹងភាពងាយច្រើន : គ្រូ–សិស្សស្តាប់គ្នាស្រួលងាយ ក្នុងការប្រាស្រ័យប្តូរចំណេះបច្ចេកទេសទាំងនេះ ព្រោះសុទ្ធសឹងជាបច្ចេកទេសដែលជាមត៌កនៅក្នុងប្រទេសយើងតែម្តង ។ តាមកម្មវិធីថ្មីនេះទៀត សៀវភៅនានា ដែលបានបោះពុម្ពជាភាសាបារាំងនៅប្រទេសបារាំង ក៏ពុំមានសៀវភៅណាមួយដែលចែងនូវវិជ្ជាឲ្យស្របទាំងស្រុងទៅលើកម្មវិធីថ្នាក់និមួយ ៗ ក៏ទេដែរ ព្រោះនិន្នាការ

បច្ចុប្បន្ននេះ មានគោលដៅថាត្រូវរៀបចំយុវជនជំនាន់ក្រោយឲ្យទៅជាក្របខណ្ឌ ( cadres) សម្រាប់ការបង្កើតផលិតផលក្នុងប្រទេសយើងផ្ទាល់តែម្ដង ។ ដូច្នេះក្នុងកម្មវិធីថ្មីនេះ សាស្ត្រាចារ្យណាក៏ដោយ តោងប្រើវិធីសំយោគ ( procedé de synthèse ) គឺប្រមូលយកសៀវភៅសិក្សានៅគ្រប់ថ្នាក់មកផ្គុំប្រមូល ទើបរៀបចំមេរៀនឲ្យសិស្សសិក្សាបាន ។

បើដូច្នេះ ដើម្បីងាយស្រួល គួរតែឲ្យបារាំងគេរៀបរៀងបោះពុម្ពសៀវភៅសិក្សាតាមកម្មវិធីថ្នាក់និមួយ ៗ តាមមុខវិជ្ជាសម្រាប់យើង ។ វិធីនេះឃើញថាខាតរូបិយបណ្ណជាអនេក ហើយអ្នកនិពន្ធបារាំងនោះទៀតសោត ក៏ប្រហែលជាពុំដឹងអំពីគោលបំណងរបស់យើងឲ្យបានច្បាស់លាស់ដែរ ។

ហេតុផលទាំងនេះ ដល់ពិចារណាទៅ គួរតែយើងប្រជុំគ្នាធ្វើសៀវភៅសិក្សាយើង ដោយពឹងផ្អែកលើយើង សម្រាប់ការប្រើប្រាស់របស់យើង ព្រមទាំងឲ្យស្របតាមកម្មវិធីយើង ។

កត្តាដែលអាចញុំាងឲ្យយើងប្រតិបត្តិទៅកើតគឺ :

— គណៈកម្មការប្រែពាក្យ សព្ទ សំនួនពាក្យក៏បានធ្វើការជាយូរឆ្នាំណាស់មកហើយដែរ ។

— ពាក្យដែលប្រែហើយក៏មានចំនួនជួនល្មម នឹងការត្រូវការ ។

— ពាក្យថ្មីៗ ដែលបង្កើតឡើង ក៏មានវត្តមានយ៉ាងបរិបូណ៌ដែរ ។

— សព្ទវចនៈដែលចូលក្នុងបច្ចេកទេស វិទ្យាសាស្ត្រប្រែពុំកើត ក៏អាចទុកប្រើដដែលទៅក៏បាន ដោយគ្រាន់តែមានពាក្យបារាំង ឬ អង់គ្លេសបិតនៅក្នុងក្រចកជាប់នៅក្បែរនោះទៅ ។

— រូបមន្ត ( formule ) វិទ្យាសាស្ត្រនានាក៏អាចចាត់ទុកជាអក្សរបរទេសក៏បាន ព្រោះគ្រាន់តែជាតំណាងប៉ុណ្ណោះ ឧបមាដូចជា $H_2O$ ជាដើម ។

កត្តាទាំងប៉ុន្មាននេះ ជម្រុញទៅភ្ជាប់នឹងការសម្រេចចិត្តរបស់សាស្ត្រាចារ្យខ្មែរ ដើម្បីនឹងជួយឧបត្ថម្ភកិច្ចការនេះ ឲ្យបាននូវលទ្ធផលជាស្ថាពរ ។

តាមការសន្មតរបស់ខ្ញុំ ប្រហែលនឹងបានដល់ទៅសមិទ្ធិ (Réalisation) ទៅកើត ។ ប្រទេសចិនប្រជាមានិត (តាមបន្ទូលរបស់អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ កាលព្រះអង្គគង់ជាទេសរដ្ឋមន្ត្រីក្រសួងអប់រំជាតិ) បានចាប់យកបញ្ហាភាសាគេមកពិនិត្យ ដើម្បីឲ្យមានឯកភាពត្រឹមត្រូវទៅវិញហើយ តែត្រូវប្រើពេលវេលាយូរបន្តិច ៗ ដូច្នេះ បើប្រសិនជាយើងចាប់ផ្តើមធ្វើការយើងបន្តិចម្តង ៗ ទៅ ប្រហែលមុខជានឹងសម្រេច ដូចមានគម្រោងការណ៍ខាងក្រោមនេះដែលជាមតិផ្ទាល់របស់ខ្ញុំ :

ដោយហេតុថា មានការស្នើពីគណៈកម្មាធិការនាយកនៃសមាគមសាស្ត្រាចារ្យខ្មែរ ដែលបានសម្រេចថា នឹងជួយឧបត្ថម្ភ យ៉ាងស្មោះអស់សមត្ថភាព ក្នុងចិត្ត-កាយ ដើម្បីការលូតលាស់នៃភាសាជាតិក្នុងសិក្សាធិការយើង នោះយោបល់ផ្ទាល់របស់ខ្ញុំយល់ឃើញថា គួរតែប្រគល់ឲ្យគណៈកម្មាធិការនាយក នៃសមាគមសាស្ត្រាចារ្យខ្មែរ គេចាប់ធ្វើការប្រែក្តី ឬតែងក្តី នូវសៀវភៅសិក្សានានាតាមការគួរដែលធ្វើបាន ដូចជាមានការតែងតាំងជាគណៈកម្មការសរសេរសៀវភៅជាខេមរភាសា តាមមុខវិជ្ជានានា ៗ កាលណាធ្វើរួចស្រេចកាលណា ដោយមាននាមលោកអ្នកនិពន្ធនៅលើសៀវភៅនោះ ទុកសិទ្ធិឲ្យអស់លោកទាំងនោះ ក្រសួងអប់រំជាតិយើងតែងតាំងគណៈកម្មការពិនិត្យ នូវស្នាដៃលោកទាំងនោះ សម្រេចថាគួរ ឬពុំគួរយកជាការបាន គឺគណៈកម្មការពិនិត្យនេះវិនិច្ឆ័យលើផ្នែកគរុកោសល្យ លើផ្នែកបច្ចេកទេស លើអត្តរូប (la forme) នៃអត្ថបទ (textes) ព្រមទាំងលើអត្ថន័យ (le fond) ជាដើម ។ មុខវិជ្ជាដែលគួរចាប់មកធ្វើមានដូចជាប្រវត្តិវិទ្យា (l'Histoire) ភូមិវិទ្យា (la Géographie) វិទ្យាសាស្ត្រធម្មជាតិ (Sciences Naturelles) ចរិយាវិទ្យា (Morale) ការអប់រំពលរដ្ឋ (Education civique) ជាដើម ។ ដល់ពិនិត្យទៅហើយ គណៈកម្មការពិនិត្យនេះសម្រេចថា ត្រឹមត្រូវ ជាគួរហើយ នោះក្រសួងអប់រំជាតិ

បង្ក្រង់ជាសៀវភៅបណ្ដោះអាសន្នរាយដោយអង្គុលីលេខចែកជូនទៅគ្រប់សាលា សុំឲ្យពិនិត្យដាក់អនុវត្តបណ្ដោះអាសន្នក្នុងឆ្នាំសិក្សាណាមួយ ។ លទ្ធផលនៃការអនុវត្តបណ្ដោះអាសន្ននេះ ត្រូវធ្វើជាសេចក្ដីរាយការណ៍ ពីសាស្ត្រាចារ្យនានាទាំងនាយកមធ្យមគ្រឹះស្ថាននានា យកមកពិនិត្យពិចារណាវែកញែករកខុសថ្មីដាក់បន្ថែម ដើម្បីឲ្យកាន់តែប្រសើរឡើង ។ បានដូច្នេះហើយ យកទៅអនុវត្តឆ្នាំសិក្សាទីពីរទៀត យកសេចក្ដីរាយការណ៍មកសិក្សាពិនិត្យទៀត ម្ដងនេះយកជាការកែម្ដងក៏បាន ឬ បន្តការអនុវត្តល្បងមើលទៀតនៅឆ្នាំសិក្សាទីបី បំណងនេះគឺចង់ឲ្យកិច្ចការនេះបានដំហរមាំ ។ សៀវភៅសិក្សា នៅប្រទេសណាក៏ដោយ តែងតែត្រូវមានការសម្រួល កែតម្រូវ បន្ថែម ឲ្យបានប្រណិតឡើងជានិច្ច ។

រីឯអ្នកនិពន្ធដែលទទួលមុខងារសរសេរ ក៏ចេះតែធ្វើការតៗទៅ ឲ្យមានសៀវភៅមុខវិជ្ជាមួយៗ គ្រប់គ្រាន់ សម្រាប់គ្រប់ថ្នាក់ ។

ខ្ញុំឃើញតែផ្លូវនេះទេ ដែលអាចមានប្រកបពេញរូបខ្លះ ។

និន្នាការសព្វថ្ងៃវាដើរតាមមាគ៌ានេះហើយ បើប្រសិនជាយើងពុំចាប់យកមកគិត ពុំដឹងជាកាលណាយើងចាប់យកមកប្រតិបត្តិនូវការងារនេះឡើយ តែចាំឲ្យទេសកាលជំរុញមកឲ្យយើងនេះ ក្រែងនាំឲ្យយើងចាត់ការពុំទាន់ហើយពុំបានល្អទៀត ។

## ខ.- អត្ថទោស

ក្នុងគម្រោងការណ៍ ដែលខ្ញុំបានគ្រោងជាគំនិតផ្ទាល់ខាងលើ អាចនឹងមានជាផលវិបាកខ្លះ ដូចជាការខ្វះនូវសាស្ត្រាចារ្យដែលចេះនូវភាសាខ្មែរឲ្យបានច្បាស់លាស់ ការអនុវត្តឲ្យបានជាស្ថាពរ ការខ្វះនូវឧបករណ៍នានា ជាដើម ។

បំពោះបុគ្គលិកនោះ តាមយោបល់ផ្ទាល់របស់ខ្ញុំ ឃើញថាពុំខ្វះជាដាច់ខាត ដោយខេមរភាសាសព្វថ្ងៃនេះមានល្បឿនលឿនសម្បើមណាស់ ។ គេសិក្សាខេមរភាសាមានបែបបទត្រឹមត្រូវណាស់ ពុំដូចជំនាន់បារាំង ឬក្រោយពីពេលពីក្រញាំអាណានិគមបារាំងនេះភ្លាមនោះទេ ។

*បំពោះបញ្ហាឯទៀតៗនោះ ជាការបន្ទាប់បន្សំ ដែលអាចដោះស្រាយទៅបាន ដូចកាលយើងបានហែហមសម្តេចឪយើង នាសម័យបូជនីយកិច្ច ។*

*សូមសហជីវិនទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។*

*ភ្នំពេញ នៅថ្ងៃ ទី ១៩ ខែធ្នូ ១៩៦៦*

នាយកមធ្យមសិក្សា : កែវ បែម

តទៅទំព័រ ប៉

— Mais Monsieur, s'ils ne sont pas bons en français, en d'autres matières, ils sont vraiment du tonnerre ! ! !

— Vous sortez du sujet, Monsieur, on ne parle ici que du français, langue véhicule de l'enseignement Khmer. Et vous comprenez sans doute, l'importance de la langue véhicule. Quand un candidat sort du sujet à l'examen, il aura zéro. Rappelez-vous bien cela !

Le fait d'être « bon en d'autres matières » n'excuse pas la faiblesse en question. Puisque nous enseignons le français à nos élèves, il faut bien qu'ils connaissent cette langue. Autrement le mieux est de ne pas le faire.

Car on ne « casse pas la sueur » (1) pour rien ; on ne se fait pas tirer « les feuilles d'oreille » (2) pour rien. Mieux vaut une belle pomenade sur « la hanche de la montagne » (3) que de regarder le tableau jusqu'à « vouloir casser l'œil » (4).

On « ne joyeux pas » (5) hein !

---

1, 2, 3, 4, 5 = phrases extraites des copies des candidats aux divers examens ( Diplôme et Concours Professionnels )




# បញ្ហាខេមរនីយកម្ម

អនុលោមតាមសេចក្តីសំរេចរបស់មហាសន្និបាត គ.នាយកបានផ្ញើលិខិតមួយច្បាប់ស្តីពីបញ្ហាខេមរនីយកម្ម ទៅជូនសហ.រដ្ឋមន្ត្រីអប់រំជាតិ ។ តបមកវិញ សហ.រដ្ឋមន្ត្រីបានផ្ញើលិខិតមកសួរយោបល់យើង ចំពោះផែនការរៀបចំ ខេមរនីយកម្ម ដោយបានឲយើងថ្លឹងមើលនូវផលវិបាកផ្សេង ៗ ដែលអាចហូរចេញមកពីខេមរនីយកម្មនេះផង ។ ក្រោយពីបានប្តូរយោបល់គ្នាចំពោះបញ្ហានេះហើយ យើងក៏បានជូនយោបល់របស់យើងទៅក្រសួងអប់រំជាតិវិញ នៅក្នុងលិខិតមួយច្បាប់ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

*ភ្នំពេញ ថ្ងៃទី ៧ វិច្ឆិកា ១៩៦៦*

គណៈកម្មាធិការនាយក នៃ សមាគមសាស្ត្រាចារ្យខ្មែរ
សូមជំរាបមកសហជីវិនី រដ្ឋលេខាធិការ នៃក្រសួងអប់រំជាតិ សូមជ្រាប

## កម្មវត្ថុ : បញ្ហាខេមរនីយកម្មនៃការសិក្សា

យោង : លិខិតសហជីវិន រដ្ឋមន្ត្រីក្រសួងអប់រំជាតិ ចុះថ្ងៃ ១៦-៩-៦៦ ចំពោះ ស.ស.១

*តបតាមសំបុត្រខាងលើ ដែលសហជីវិនរដ្ឋមន្ត្រីសួរទៅ ស.ស.១. ថាគប្បីរៀបចំផែនការទៅបែបណា ដើម្បីធ្វើខេមរនីយកម្មក្នុងអនាគត យើងខ្ញុំនៅក្នុងគណៈកម្មាធិការនាយក ក្រោយពីបានពិភាក្សាគ្នាហើយ សូមជូនយោបល់ដូចតទៅ :*

បញ្ហាផែនការនៃខេមរនីយកម្ម ជាបញ្ហានយោបាយសិក្សាធំណាស់ ទាក់ទងទៅនឹងកត្តាច្រើនយ៉ាង ដូច្នេះក្រែងជ្រុលហួសក្របខ័ណ្ឌនៃសមត្ថកិច្ចសមាគមយើងខ្ញុំ ។ ប៉ុន្តែ ក្នុងឋានៈជាសាស្ត្រាចារ្យ យើងខ្ញុំសូមផ្តល់គំនិតលើចំណុចខ្លះ ដើម្បីជាវិភាគទានលើរឿងនេះ ។

ក្នុងមតិសាស្ត្រាចារ្យ ដូចជាក្នុងឱកាសមហាសន្និបាតសមាគមក្តី ឬក្នុងការប្រជុំនាយកវិទ្យាស្ថានមធ្យមសិក្សាសម័យខ្លះក្តី មានគំនិតស្របគ្នាថា ខេមរនីយកម្មខាងសិក្សាគួរតែធ្វើ ហើយធ្វើដោយសន្សឹម ៗ នឹងតាមផែនការដ៏ច្បាស់លាស់សំរាប់អនាគតយ៉ាងវែង ។

តាមយោបល់យើងខ្ញុំ បើសិនអ្នកទទួលខុសត្រូវទាំងអស់នៃក្រសួងអប់រំស្រុះស្រួលគ្នាលើគោលការណ៍ខាងលើនេះហើយ ជំហានទីមួយដែលគប្បីធ្វើគឺ ការតែងតាំងគណៈកម្មការមួយឲ្យបកប្រែ ឬតែងសៀវភៅសិក្សាជាភាសាជាតិ ។

សព្វថ្ងៃនេះ តាមព្រះរាជបញ្ជានៃសម្តេចព្រះបិតាសិក្សាធិការជាតិ ក្រសួងអប់រំកំពុងរៀបចំអនុវត្តកម្មវិធីថ្មី ។ ប៉ុន្តែគ្មានសៀវភៅបារាំងណាមួយ អាចយកមកប្រើឲ្យចំថ្នាក់តាមកម្មវិធីថ្មីនេះទេ សាស្ត្រាចារ្យគោងតែធ្វើការសំយោគដោយដកស្រង់ពីសៀវភៅបារាំងច្រើនថ្នាក់ យកមកប្រែក្រឡៃខ្លួនឯងទៀត ។ ដើម្បីឲ្យការប្រែសមនឹងបច្ចេកទេសគរុកោសល្យ នឹងដើម្បីឲ្យមានឯកភាពក្នុងអត្ថបទបង្រៀនក្នុងព្រះរាជាណាចក្រទាំងមូល ត្រូវតែមានសៀវភៅជាមូលដ្ឋានសំរាប់សិស្សនឹងគ្រូ ។ ដូច្នេះ ការតែងសៀវភៅឲ្យស្របទៅនឹងកម្មវិធីថ្មីជាការចាំបាច់ ដើម្បីអនុវត្តកម្មវិធីនេះឲ្យបានប្រសិទ្ធភាព ។ តើយើងតែងសៀវភៅជាភាសាបារាំង ឬជាភាសាខ្មែរ? យើងខ្ញុំយល់ឃើញថា តែងជាភាសាបារាំងពុំកើតទេ ទោះជាចិត្តយើងចង់ ក៏ពុំអាចសរសេរបានល្អដូចបារាំងដែរ ហើយនាំតែគេរិះគន់បំអកឲ្យផង ។ ឱកាសអនុវត្តកម្មវិធីថ្មីនេះ ជាឱកាសល្អដែលហុចឲ្យយើងចាប់ផ្តើមសរសេរសៀវភៅជាភាសាខ្មែរសំរាប់មធ្យមសិក្សាក៏ដូចជាបឋមសិក្សា ។ ក្នុងមធ្យមសិក្សា ក្រសួងអាចចាត់តាំងគណៈកម្មការមួយមានសាស្ត្រាចារ្យចំណាន ៗ ដប់ ឬ ដប់ប្រាំនាក់ទទួលភារៈតែងសរសេរ

សៀវភៅសំរាប់ថ្នាក់ទី ៦ ក្នុងរវាងមួយឆ្នាំឲ្យហើយ ។ រួចឆ្នាំបន្ទាប់ សរសេរសំរាប់ថ្នាក់ទី ៥ គ ១ លុះតែគ្រប់ថ្នាក់នៃមធ្យមសិក្សា ។

ម្យ៉ាងទៀត ក្រសួងបានអនុញ្ញាតឲ្យសាស្ត្រាចារ្យបង្រៀនប្រវត្តិវិទ្យា និងភូមិវិទ្យាជាភាសាខ្មែរ នៅថ្នាក់ទី ៦ រួចទៅហើយ ប៉ុន្តែដំណើរការណ៍នេះក៏នៅតែត្រឹមនេះ ។ យើងខ្ញុំយល់ឃើញថា គួរតែបន្តវិធានការនេះដល់ថ្នាក់ទី ៥ ទី ៤ និងទី ៣ ទៅទៀត ហើយបញ្ញាត្តដល់ពេលប្រឡងសញ្ញាបត្របឋមភូមិ DESPC ឲ្យបេក្ខជនឆ្លើយវិញ្ញាសាខាងប្រវត្តិវិទ្យានិងភូមិវិទ្យាជាភាសាជាតិ នេះក៏ជាការប្រពៃមួយដែលអាចធ្វើបានក្នុងអនាគតដ៏ខ្លី ។

យើងខ្ញុំសូមជូនយោបល់តែលើចំណុច ២ នេះ តាមគំនិតដ៏ស្ដួចស្ដើងរបស់ខ្លួន ដោយយល់ថាក្នុងបញ្ហាខេមរនីយកម្ម ចំណុចពីរនេះ គួរធ្វើមុនគេ ។ យើងខ្ញុំបានតាំងចិត្តជាស្រេចថា នឹងផ្តល់ការឧបត្ថម្ភយ៉ាងស្មោះអស់សមត្ថភាពក្នុងចិត្ត - កាយ ដល់ក្រសួងអប់រំ ដើម្បីការលូតលាស់នៃភាសាជាតិក្នុងសិក្សាធិការយើង ។

សូមសហជីវិន ទទួលនូវសេចក្តីគោរពនិងរាប់អានដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

---

អ្នកខ្លះថា " សិស្សស្រឡាញ់តែលោកគ្រូបង្រៀនមុខវិជ្ជានេះ ហើយស្អប់លោកគ្រូដែលបង្រៀនមុខវិជ្ជានោះណាស់ ។ បានសេចក្តីថា គឺមុខវិជ្ជានេះឯងដែលធ្វើឱ្យសិស្សស្រឡាញ់ ឬស្អប់លោកគ្រូម្នាក់ៗ " ។

តើមិត្តធ្លាប់បានពិចារណាមតិខាងលើនេះឬទេ ?

បើធ្លាប់ពិចារណាតែក្នុងចិត្តម្នាក់ឯង ម្តងនេះ សូមមិត្តពិចារណាលើក្រដាស ហើយផ្ញើក្រដាសនោះមកទស្សនាវដ្តីយើងកុំខាន !